ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការយុទ្ធសាស្ត្រ

## ស្តីពី

## ការប្រាស្រ័យឆ្លើយឆ្លង និង
## ទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា
## រយៈពេល ៥ឆ្នាំ ( ២០១១_២០១៥ )

ឆ្នាំ ២០១០

# មាតិកា

ទំព័រ

១-សេចក្តីផ្តើម ........ ១

២-ប្រវត្តិរបស់ស្ថាប័នព្រឹទ្ធសភា ........ ២

៣-ស្ថានភាពបច្ចុប្បន្ន ........ ៣

៣.១-តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ........ ៣

ក-មុខងារតំណាង ........ ៤

ខ-មុខងារនីតិកម្ម ........ ៤

គ-មុខងារត្រួតពិនិត្យ ........ ៤

៣.២-ទីតាំង និងសារៈសំខាន់របស់ព្រឹទ្ធសភា ........ ៤

៣.៣-ស្នាដៃដែលសម្រេចបាន ១៩៩៩-២០១០ ........ ៥

៣.៤-ស្ថានភាពធនធាន ........ ៧

៣.៤.១-ទីកន្លែង និងមធ្យោបាយ ........ ៧

៣.៥-ចំណុចខ្លាំង និងចំណុចខ្សោយ ........ ៩

៣.៥.១-ចំណុចខ្លាំង ........ ៩

៣.៥.២-ចំណុចខ្សោយ ........ ១០

៣.៦-ឱកាស និងការគម្រាមកំហែង ........ ១២

៣.៦.១-ឱកាស ........ ១២

៣.៦.២-ការគម្រាមកំហែង ........ ១៤

៤-ស្ថានភាពអនាគត ........ ១៥

៤.១_ចក្ខុវិស័យ និងបេសកកម្ម ........................................ ១៥
៤.១.១_ចក្ខុវិស័យ ........................................ ១៥
៤.១.២_បេសកកម្ម ........................................ ១៥
៤.២_កត្តាកំណត់ជោគជ័យ និងសក្តានុពលរបស់ព្រឹទ្ធសភា ..... ១៥
៤.២.១_កត្តាកំណត់ជោគជ័យ ........................................ ១៥
៤.២.២_សក្តានុពល ........................................ ១៧
៤.២.៣_អាទិភាពចម្បង ........................................ ១៨
៤.៤_គោលដៅជាយុទ្ធសាស្ត្រ ........................................ ១៩
៤.៥_គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ ................ ២១
៥_សេចក្តីសន្និដ្ឋាន ........................................ ៣១

* ផែនការយុទ្ធសាស្ត្រប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនង
សាធារណៈរបស់ព្រឹទ្ធសភារយៈពេល៥ឆ្នាំ ២០១១_២០១៥
តារាងសង្ខេបលំអិតអំពីគោលដៅ សកម្មភាព ពេលវេលា
ធនធាន លទ្ធផលរំពឹងទុក សន្ទស្សន៍ស្ថានភាពអំណោយផល
និងហានិភ័យដែលអាចកើតមាន ........................................ ៣៣

# ១. សេចក្ដីផ្ដើម

ផែនការយុទ្ធសាស្ត្រប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា រយៈពេល០៥ឆ្នាំ (២០១១-២០១៥) ត្រូវបានរៀបចំចងក្រងឡើងក្នុងគោលបំណងពង្រឹងពង្រីកចំណងទាក់ទងរវាងព្រឹទ្ធសភា និងក្រុមប្រឹក្សាឃុំ-សង្កាត់ ស្ថាប័នជាតិ ក្រោមជាតិ សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ សាធារណជន ព្រមទាំងបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងសភាបរទេសនៅលើពិភពលោក ។

ផែនការនេះ សំដៅបើកទូលាយនូវការប្រាស្រ័យឆ្លើយឆ្លងរបស់ស្ថាប័នព្រឹទ្ធសភា និងផ្ដល់ជូនសាធារណជនឱ្យយល់កាន់តែច្បាស់អំពីតួនាទីរបស់ព្រឹទ្ធសភាក្នុងនាមជាស្ថាប័ននីតិប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ដែលមានមុខងារសំខាន់បី គឺមុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ ។ ទន្ទឹមនឹងនេះ ការរៀបចំកសាងផែនការយុទ្ធសាស្ត្រប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា មានគោលបំណងអនុវត្ត និងឆ្លើយតបឱ្យបានស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០០៨-២០១៨) ដែលនឹងអាចជួយជំរុញឱ្យស្ថាប័នបំពេញការងារប្រកបដោយសុគតិភាព ចីរភាព និងមានការអភិវឌ្ឍជាលំដាប់ ។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រនេះ ព្រឹទ្ធសភាត្រូវអនុវត្តប្រកបដោយភាពទន់ភ្លន់ រស់រវើក បត់បែន និងឆ្នៃប្រឌិត ទៅតាមកាលៈទេសៈ ព្រមទាំងសម្របសម្រួលទៅតាមស្ថានភាពដែលអាចកើតមានឡើង ។ ដូច្នេះ

ផែនការយុទ្ធសាស្ត្រនេះ ចាំបាច់ត្រូវមានការត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់ ដើម្បីពិនិត្យ និងវាយតម្លៃរកលទ្ធផលដែលសម្រេចបាន និងផលប៉ះពាល់ក្នុងអំឡុងពេលអនុវត្តផែនការយុទ្ធសាស្ត្រនេះ។

## ២. ប្រវត្តិរបស់ស្ថាប័នព្រឹទ្ធសភា

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នាថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ បានកំណត់ឱ្យមានការបោះឆ្នោតជាសកល ដោយសេរី និងយុត្តិធម៌ក្នុងប្រទេសកម្ពុជា ក្រោមការរៀបចំរបស់អាជ្ញាធរបណ្តោះអាសន្ន នៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា ហៅកាត់ថា **(UNTAC)** ដើម្បីបញ្ចប់ជម្លោះ បង្កើតស្ថាប័នគ្រប់គ្រងប្រទេស និងកសាងនីតិរដ្ឋ។

ការបោះឆ្នោតជាសកលលើកដំបូង បានប្រព្រឹត្តទៅនាថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣។ សភា ធម្មនុញ្ញមួយបានចាប់បដិសន្ធិឡើង នាថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៩៣ ដើម្បីតាក់តែងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សភាធម្មនុញ្ញ បានអនុម័តរដ្ឋធម្មនុញ្ញនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣ ហើយបានក្លាយមកជារដ្ឋសភានីតិកាលទី១ ដែលបានដំណើរការពេញ០៥ឆ្នាំ។

ក្រោយពីការបោះឆ្នោតសកលនាឆ្នាំ១៩៩៨ កម្ពុជាបានជួបវិបត្តិនយោបាយផ្ទៃក្នុង។ ប៉ុន្តែវិបត្តិនេះ ត្រូវបានដោះស្រាយរួចដោយកម្ពុជាខ្លួនឯង នាកិច្ចប្រជុំថ្នាក់ដឹកនាំជាន់ខ្ពស់នៃគណបក្សធំទាំងពីរ នាថ្ងៃទី១២-១៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** នាព្រះបរមរាជវាំង។ កិច្ចប្រជុំបានសម្រេច

បង្កើតព្រឹទ្ធសភា ដោយធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញផ្តល់ឱកាសឱ្យកម្ពុជាប្រកាន់របបសភាពីរ ។

ព្រឹទ្ធសភានីតិកាលទី១ កើតឡើងដោយសារការតែងតាំង និងមានអាណត្តិចំនួន៥ឆ្នាំ។ សមាជិក ព្រឹទ្ធសភានីតិកាលទី១មានចំនួន ៦១រូប មកពីគណបក្សនយោបាយចំនួនបី ។ ព្រឹទ្ធសភានីតិកាលទី១ បានបើកសម័យប្រជុំលើកទី១ នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩៩ ។

ព្រឹទ្ធសភានីតិកាលទី២ កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃទី២២ ខែមករា ឆ្នាំ២០០៦ ដោយមានអាណត្តិចំនួន៦ឆ្នាំ ។ ក្នុងចំណោមសមាជិក ៦១រូប មាន ៥៧រូប ត្រូវបានជ្រើសរើសដោយការបោះឆ្នោតអសកល ០២រូប ជ្រើសតាំងដោយរដ្ឋសភា និង ០២រូបទៀត តែងតាំងដោយព្រះមហាក្សត្រ ។ ព្រឹទ្ធសភានីតិកាលទី២ បើកសម័យប្រជុំដំបូងរបស់ខ្លួន នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ។

# ៣. ស្ថានភាពបច្ចុប្បន្ន

## ៣.១ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា

ព្រឹទ្ធសភា ជាស្ថាប័ននីតិប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ដែលមានភារកិច្ចសម្រិតសម្រាំងច្បាប់ឱ្យបានល្អ និងធ្វើការសម្របសម្រួលការងាររវាងរដ្ឋសភា និងរាជរដ្ឋាភិបាល ។ ក្នុងតួនាទីជាស្ថាប័ននីតិប្បញ្ញត្តិ ព្រឹទ្ធសភាមានមុខងារសំខាន់ៗចំនួនបី គឺ មុខងារតំណាង មុខងារនីតិកម្ម និងមុខងារត្រួតពិនិត្យ ។

**ក-មុខងារតំណាង ៖** សមាជិកព្រឹទ្ធសភាភាគច្រើនជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាម្ចាស់ឆ្នោតនៅភូមិភាគ និងតំណាងឱ្យប្រជាជាតិខ្មែរទាំងមូល ។ លើសពីនេះទៀតក៏មានតំណាងព្រះមហាក្សត្រ និងតំណាងរដ្ឋសភាផងដែរ ។

**ខ-មុខងារនីតិកម្ម ៖** កិច្ចការនីតិកម្មរបស់ព្រឹទ្ធសភាស្តែងឡើង តាមរយៈការធ្វើរបាយការណ៍ ពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ ឬបញ្ហាផ្សេងៗដែលបានដាក់ជូនឱ្យព្រឹទ្ធសភាពិនិត្យ ។

**គ-មុខងារត្រួតពិនិត្យ ៖** ព្រឹទ្ធសភាធ្វើការតាមដានត្រួតពិនិត្យការងាររបស់រាជរដ្ឋាភិបាល និងការអនុវត្តច្បាប់ជាធរមាន ។ ប៉ុន្តែជាទូទៅ ព្រឹទ្ធសភាពុំដើរតួនាទីប្រឆាំង ឬគាំទ្ររាជរដ្ឋាភិបាលឡើយ ។ ព្រឹទ្ធសភាមានបេសកកម្មផលិតច្បាប់ឱ្យបានល្អ ដែលជាគោលដៅអាទិភាពដោយមិនចំណុះបរិយាកាសនយោបាយ និងកាលៈទេសៈ ។

## ៣.២ តួនាទី និងសារៈសំខាន់របស់ព្រឹទ្ធសភា

ព្រឹទ្ធសភា គឺជាអង្គការនីតិបញ្ញត្តិរបស់ជាតិ ដែលដើរតួនាទីសំខាន់ក្នុងដំណើរការប្រជាធិបតេយ្យភាវូបនីយកម្មសង្គម និងក្នុងការកសាងកម្ពុជាជានីតិរដ្ឋ ។ មុខងារសំខាន់មួយទៀត គឺការរួមវិភាគទានក្នុងដំណើរការស្ថិរភាពភាវូនីយកម្មជីវភាពនយោបាយរបស់ជាតិ ជាស្នូលនៃការពង្រឹងនយោបាយបង្រួបបង្រួម ផ្សះផ្សាជាតិ និងអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនរុងរឿង និងសម្បូរសប្បាយ ។

ព្រឹទ្ធសភា កំពុងផ្សារភ្ជាប់ខ្លួនទៅនឹងដំណើរការវិមជ្ឈការ វិសហមជ្ឈការ ជាបច្ចុប្បន្នភាពនៃការកំណែទម្រង់រដ្ឋបាលសាធារណរបស់ជាតិ។

## ៣.៣ ស្នាដៃដែលសម្រេចបាន ១៩៩៩-២០១០

គិតចាប់តាំងពីពេលព្រឹទ្ធសភាត្រូវបានបង្កើតឡើងមកទល់ពេលនេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ព្រឹទ្ធសភាបានរួមចំណែកជួយដោះស្រាយបញ្ហាជាច្រើនសម្រាប់បម្រើដល់ការគ្រប់គ្រងរដ្ឋ គ្រប់គ្រងសេដ្ឋកិច្ច គ្រប់គ្រងសង្គមកិច្ច ព្រមទាំងតម្រូវការនៃការធ្វើសមាហរណកម្មកម្ពុជានៅក្នុងក្របខ័ណ្ឌតំបន់ និងលើឆាកអន្តរជាតិ។

ដោយឡែកលើការងារប្រាស្រ័យឆ្លើយឆ្លង ព្រឹទ្ធសភាបានខិតខំផលិតជាឯកសារបោះពុម្ព និងឯកសារផ្សាយតាមប្រព័ន្ធអេឡិចត្រូនិក ផ្សព្វផ្សាយទាំងក្នុង និងក្រៅស្ថាប័ន មានដូចជា៖ សមិទ្ធផលព្រឹទ្ធសភា នីតិកាលទី១ និងសម្រាប់រយៈពេល១០ឆ្នាំ ព្រឹត្តិបត្រប្រចាំខែរបស់ព្រឹទ្ធសភា ព្រឹត្តិបត្រព័ត៌មានប្រចាំថ្ងៃ រៀបចំដំណើរទស្សនកិច្ចសិក្សារបស់សិស្ស និស្សិត និងមន្ត្រីសភាបរទេស ច្បាប់បោះឆ្នោតព្រឹទ្ធសភា ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ច្បាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ សៀវភៅបត់ស្តីពីព្រឹទ្ធសភានីតិកាលទី២ និងសកម្មភាពសមាជិកព្រឹទ្ធសភាតាមភូមិភាគទាំង៨ សៀវភៅស្តីអំពីចក្ខុវិស័យ បេសកកម្ម និងគោលដៅរបស់សមាជិកព្រឹទ្ធសភានីតិកាលទី២ ការរៀបចំវេទិកាទាំង៨ភូមិភាគទូទាំងប្រទេស ក្របខ័ណ្ឌ

យុទ្ធសាស្ត្រ និងផែនការសកម្មភាពរបស់ព្រឹទ្ធសភា និងសៀវភៅ ស្ដីពីនីតិកាលទី២ របស់ព្រឹទ្ធសភា ។

ព្រឹទ្ធសភា ក៏បានផលិតខ្សែ **Video** ស្ដីពីសមិទ្ធផលប្រចាំឆ្នាំ និង១០ឆ្នាំរបស់ព្រឹទ្ធសភា វេទិកាតាមភូមិភាគក្នុងបរិវេណព្រឹទ្ធសភា សកម្មភាពថ្នាក់ដឹកនាំ សមាជិក សមាជិកា ក្នុងការប្រជុំអនុម័តច្បាប់ សិក្ខាសាលា ។ល។ ដើម្បីផ្សព្វផ្សាយតាមរយៈ វិទ្យុ ទូរទស្សន៍ ជូនប្រជាពលរដ្ឋបានជ្រាប ។

ទន្ទឹមនេះដែរ ក្នុងរយៈពេលកន្លងមកនេះ ព្រឹទ្ធសភាបានខិតខំអនុវត្តតាមផែនការយុទ្ធសាស្ត្រ៥ឆ្នាំ របស់ព្រឹទ្ធសភា (២០០៣-២០០៨) មាន៥គោលដៅសំខាន់ ក្នុងនោះមានគោលដៅមួយកំណត់ពីការផ្សព្វផ្សាយព័ត៌មានដែលអនុវត្តទទួលបានលទ្ធផលផ្លែផ្កាគួរជាទីកត់សម្គាល់ ។ ការផ្សព្វផ្សាយព័ត៌មាននេះ ក៏មានជួបការលំបាកខ្លះៗដែរ ដោយហេតុថាភាគច្រើនពាក់ព័ន្ធដល់បញ្ហាថវិកាដែលត្រូវចំណាយ និងភាពទន់ខ្សោយខាងបច្ចេកទេស និងនិពន្ធរបស់មន្ត្រីទទួលបន្ទុកខាងការងារព័ត៌មាន។ ក៏ប៉ុន្តែទោះជាយ៉ាងនេះក្ដី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានរៀបចំឯកសារ ឬព័ត៌មានផ្សេងៗរបស់ព្រឹទ្ធសភា ធ្វើការផ្សព្វផ្សាយតាមរយៈសារព័ត៌មាន វិទ្យុ ទូរទស្សន៍ជាតិ និងទូរទស្សន៍ឯកជន និងបានត្រៀមបណ្ដុះបណ្ដាលមន្ត្រីបុគ្គលិកឱ្យចេះរបៀបគ្រប់គ្រង របៀបប្រតិបត្តិការ ការថែរក្សាបច្ចេកវិទ្យា និងឧបករណ៍ផ្សព្វផ្សាយព័ត៌មាន។ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាក៏បានលើកកម្ពស់ និងកែលំអជាបណ្ដើរៗនូវគុណភាពព្រឹត្តិបត្រព័ត៌មាន គេហទំព័រ (Website) ដោយបានបញ្ចូលនូវ

សកម្មភាពការងារសំខាន់ៗជាច្រើនរបស់ព្រឹទ្ធសភា ជាពិសេសការងារទាក់ទង ទៅនឹងតួនាទីនីតិកម្ម តួនាទីត្រួតពិនិត្យ និងតួនាទីតំណាងរបស់សមាជិក ព្រឹទ្ធសភា។ ចំពោះលទ្ធភាពនៃការបង្កើតមជ្ឈមណ្ឌលឯកសារ ទោះបីបច្ចុប្បន្ន នេះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ពុំទាន់បានរៀបចំបង្កើតនៅឡើយក្តី ក៏ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានខិតខំរៀបចំជាបណ្ណសារដ្ឋានមួយ ដើម្បីតម្កល់ ឯកសារព្រឹទ្ធសភាជាបណ្តើរៗ។ ចំពោះបណ្ណាល័យ ទោះបីជាពុំទាន់ឈានដល់ បណ្ណាល័យអេឡិចត្រូនិចក្តី ក៏មានការខិតខំរកជំនួយឧបត្ថម្ភជាសៀវភៅគ្រប់ មុខតម្កល់ទុកក្នុងបណ្ណាល័យ សម្រាប់ជូនសាធារណជនចូលអាន។ ជាក់ស្តែង មានសាធារណជនចូលអានចំនួន៩២.៣១៦នាក់ និងអ្នកបើកមើល Website ព្រឹទ្ធសភាចំនួន២៣៣.៨១៥នាក់។

## ៣.៤ ស្ថានភាពធនធាន

### ៣.៤.១ ទីកន្លែង និងមធ្យោបាយ

ជាទូទៅ ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានអគារសមរម្យ ហើយបុគ្គលិកមានមូលដ្ឋានសម្ភារសមស្របសម្រាប់បំពេញការងារ។ នាឆ្នាំ ១៩៩៩ អគារចំនួន២១ ត្រូវបានជួសជុល និងកែលម្អ។ នៅឆ្នាំ២០០១ និង ២០០២ អគារថ្មីចំនួន៦ខ្នង ត្រូវបានសាងសង់រួចរួមបញ្ចូលទាំងសាលប្រជុំ ព្រឹទ្ធសភាផងដែរ ហើយគ្រប់អគារទាំងអស់មានភ្លើងអគ្គិសនី និងបំពាក់ដោយ ម៉ាស៊ីនត្រជាក់។ ឆ្នាំ២០០៩ អគារចំនួន០៣ខ្នង បានកំទេចចោល និងជំនួស ដោយអគារថ្មី០២ខ្នង០៣ជាន់ បំពាក់សម្ភារគ្រប់គ្រាន់។ តាំងពីដំបូង ហេដ្ឋា-

រចនាសម្ព័ន្ធទូទៅនៅព្រឹទ្ធសភា ពោលគឺការផ្គត់ផ្គង់ទឹក និងបណ្តាញផ្លូវថ្នល់ត្រូវបានជួសជុលកែលម្អឡើងវិញ។

ទាក់ទិននឹងមូលដ្ឋានសម្ភារ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាមានឧបករណ៍ការិយាល័យយ៉ាងច្រើន ក្នុងនោះរួមមានកុំព្យូទ័រចំនួន៤២៧គ្រឿង និងម៉ាស៊ីនហ្វូតូកូពីចំនួន៣៧គ្រឿង ដែលមានប្រភេទខ្នាតធំចំនួន១១គ្រឿង ខ្នាតមធ្យមចំនួន០២គ្រឿង និងប្រភេទខ្នាតតូចចំនួន២៤គ្រឿង ព្រមទាំងបានបង្កើតឱ្យមាន **Studio** និង **Website**។ មកទល់ពេលបច្ចុប្បន្ននេះ ឧបករណ៍ សម្ភារបរិក្ខារទាំងអស់មានសភាពចាស់ និងដំណើរការរអាក់រអួល ក៏ប៉ុន្តែអគ្គលេខា-ធិការដ្ឋានបានខិតខំស្នើសុំជំនួយពីម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍ ដើម្បីដោះដូរឧបករណ៍ចាស់ចេញ និងបំពាក់ឧបករណ៍ថ្មីជំនួសជាបណ្តើរៗ។ ដោយឡែកនាយកដ្ឋានព័ត៌មាន មានឧបករណ៍ សម្ភារមួយចំនួនសម្រាប់យកព័ត៌មាន ដូចជាកាមេរ៉ាវីដេអូចំនួន០៨គ្រឿង កាមេរ៉ាថតរូប (Fix) ចំនួន០៤គ្រឿង ម៉ាស៊ីនកាត់តរូបភាពចំនួន០១គ្រឿង និងក្បាលថតកាសែត DV ចំនួន០២គ្រឿង។ ស្ទូឌីយ៉ូមួយកំពុងរៀបចំឡើងវិញ ទន្ទឹមនឹងការបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកផ្នែកនេះ។ ទន្ទឹមនឹងនេះដែរ នាយកដ្ឋានព័ត៌មានវិទ្យា បាននិងកំពុងរៀបចំប្រព័ន្ធ **Network, Internet** នៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។ គេហទំព័រ **(Website)** របស់ព្រឹទ្ធសភាត្រូវបានកែលំអជាបន្តបន្ទាប់។ ក្រៅពីនេះ យើងមានកិច្ចសហប្រតិបត្តិការល្អជាមួយនឹង **ICT Global Center** នៅអ៊ីតាលី និងអង្គការ **NIDA** កម្ពុជា ដើម្បីឱ្យជួយគាំទ្រការរៀបចំប្រព័ន្ធ **IT** នៅស្ថាប័នព្រឹទ្ធសភា។

## ៣.៥ ចំណុចខ្លាំង និងចំណុចខ្សោយ

### ៣.៥.១ ចំណុចខ្លាំង

- ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាមានឆន្ទៈ និងការទទួលខុសត្រូវខ្ពស់លើការងារ ប្រាស្រ័យឆ្លើយឆ្លង
- ព្រឹទ្ធសភាកសាងបាននូវផែនការយុទ្ធសាស្ត្រ៥ឆ្នាំ សម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០០៣-២០០៨) និងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០០៨-២០១៨)
- ព្រឹទ្ធសភាបានតាក់តែងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា និងកសាងឯកសារគតិយុត្តសំខាន់ៗមួយចំនួនទៀត
- ព្រឹទ្ធសភាបានកៀរគរជំនួយពីបរទេស ដើម្បីពង្រឹងសមត្ថភាពទំនាក់ទំនង និងបំពាក់ប្រព័ន្ធ **IT** ក្នុងស្ថាប័ន
- សមាជិក សមាជិកាព្រឹទ្ធសភាមានសាមគ្គីភាពផ្ទៃក្នុងល្អ មានកិច្ចសហប្រតិបត្តិការជាមួយនឹងសមាជិករដ្ឋសភា សភាបរទេស និងដៃគូអន្តរជាតិបានល្អ
- ព្រឹទ្ធសភាបានរៀបចំវេទិកានានាតាមភូមិភាគទាំង៨
- ព្រឹទ្ធសភាមាន **Studio** សម្រាប់ថតរូបភាពសម័យប្រជុំពេញអង្គរបស់ព្រឹទ្ធសភា ព្រមទាំង **Website** សម្រាប់ផ្សព្វផ្សាយព័ត៌មាន
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបង្កើតឱ្យមានបណ្ណាល័យ និង

នាយកដ្ឋានព័ត៌មានមួយ ទទួលបន្ទុកស្រាវជ្រាវ ប្រមូល និងផ្សព្វផ្សាយព័ត៌មានរបស់ព្រឹទ្ធសភា ជូនសាធារណជនជ្រាប ។

### ៣.៥.២ ចំណុចខ្សោយ

- ព្រឹទ្ធសភាពុំទាន់បានពង្រឹងតួនាទីជាតំណាងពិតប្រាកដតាមភូមិភាគទាំង៨ ឱ្យបានពេញលេញនៅឡើយ
- សមាជិកព្រឹទ្ធសភា និងគណៈកម្មការជំនាញមានលេខាធិការដ្ឋានអមគណៈកម្មការជំនាញ ព្រមទាំងខុទ្ទកាល័យអមថ្នាក់ដឹកនាំពុំទាន់យល់ច្បាស់អំពីសារៈសំខាន់នៃការប្រាស្រ័យឆ្លើយឆ្លង និងចេះធ្វើការងារទំនាក់ទំនងសាធារណៈ ប្រកបដោយផ្លែផ្កានៅឡើយ
- ព្រឹទ្ធសភាពុំទាន់បានទទួលការបណ្តុះបណ្តាលទូលំទូលាយលើការងារប្រាស្រ័យឆ្លើយឆ្លងឱ្យបានស៊ីជម្រៅ
- ពុំទាន់កសាងបាននូវមជ្ឈមណ្ឌលច្បាប់រឹងមាំ បណ្ណាល័យទំនើប និងមជ្ឈមណ្ឌលព័ត៌មានដែលមានសមត្ថភាពធានាបាននូវលំហូរព័ត៌មាន និងមជ្ឈមណ្ឌលសភា ដើម្បីធានាដល់ការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័នព្រឹទ្ធសភានៅឡើយ
- ពុំទាន់បានបញ្ចូលតួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ក្នុងកម្មវិធីសិក្សាថ្នាក់ជាតិនៅឡើយ
- ព្រឹទ្ធសភាពុំទាន់បានរៀបចំបណ្តាញប្រព័ន្ធ Network ប្រព័ន្ធ IT

បណ្តាញ Video តភ្ជាប់ជាមួយនឹងរដ្ឋសភា

- ព្រឹទ្ធសភាពុំទាន់បង្កើតបានរោងពុម្ព ដើម្បីធ្វើឱ្យមានប្រសិទ្ធភាពក្នុងដំណើរការបោះពុម្ពរបាយការណ៍នានា បោះពុម្ពអត្ថបទច្បាប់ ទស្សនាវដ្តី ព្រឹត្តិបត្រ ។ល ។ សម្រាប់ផ្សព្វផ្សាយជូនសាធារណជនឱ្យបានច្រើន និងទូលំទូលាយនៅឡើយ
- ពុំទាន់បានរៀបចំព្រឹត្តិបត្ររបស់គណៈកម្មការជំនាញ ។ ព្រឹត្តិបត្ររបស់ព្រឹទ្ធសភាពុំទាន់បានបោះពុម្ពផ្សាយឱ្យបានទៀងទាត់នូវព័ត៌មានសំខាន់ៗអំពីការសិក្សាលើអត្ថបទច្បាប់ ដែលជារបៀបវារៈនៃដំណើរការប្រជុំរបស់ព្រឹទ្ធសភា
- ការផ្សព្វផ្សាយព័ត៌មានតាមកម្មវិធីវិទ្យុ ទូរទស្សន៍ គេហទំព័រ ទស្សនាវដ្តី ។ល ។ ជូនដល់សាធារណជន ដើម្បីលើកកម្ពស់ការយល់ដឹង ពុំទាន់មានគុណភាពល្អ និងទូលំទូលាយ
- ភាគច្រើននៃសមាជិកព្រឹទ្ធសភា មន្ត្រីជំនួយការ និងមន្ត្រីគ្រប់គ្រងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ពុំទាន់បានយល់ច្បាស់ពីការប្រើប្រាស់ និងស្រាវជ្រាវតាមប្រព័ន្ធ Network និង IT
- មន្ត្រីទទួលបន្ទុកព័ត៌មានពុំទាន់មានសមត្ថភាពពេញលេញ ក្នុងការធ្វើជាអ្នកនាំពាក្យរបស់ស្ថាប័ន និងពុំទាន់យល់ច្បាស់អំពីរបៀបតាក់តែងជាអ្នកសារព័ត៌មានអាជីព ដូចជាការសរសេរ ការនិពន្ធអត្ថបទ ទស្សនាវដ្តី និងព្រឹត្តិបត្រ ។ល ។ ពុំទាន់មានគុណភាពល្អ

និងទាន់ពេលវេលានៅឡើយ

- មន្ត្រីនៃនាយកដ្ឋានដែលទទួលបន្ទុកការងារស្រាវជ្រាវ ពុំទាន់មានសមត្ថភាពពេញលេញ ដើម្បីផ្ដល់សេវាស្រាវជ្រាវព័ត៌មានជូនសមាជិកព្រឹទ្ធសភា
- សមត្ថភាពខាងផ្នែកភាសារបស់មន្ត្រីជំនួយការគណៈកម្មការ មន្ត្រីគ្រប់គ្រង និងសមាជិកព្រឹទ្ធសភាពុំទាន់មានគុណភាព
- ពុំទាន់បានចូលរួមចំណែករៀបចំបណ្តុះបណ្តាលអ្នកសារព័ត៌មានជាតិឱ្យបានយល់ដឹងអំពីព្រឹទ្ធសភាឱ្យបានច្បាស់លាស់នៅឡើយ
- ពុំទាន់បានបណ្តុះបណ្តាលគ្រូបង្គោល១០រូប លើជំនាញសេវាគាំទ្រព័ត៌មាន និងឯកសារអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាពុំទាន់បានអនុវត្តពេញលេញនៅឡើយ ។

# ៣.៦ ឱកាស និងការគម្រាមកំហែង

## ៣.៦.១ ឱកាស

- មានច្បាប់របបសារព័ត៌មាន ដែលជាត្រីវិស័យសម្រាប់ការផ្សព្វ-ផ្សាយព័ត៌មាន
- អង្គការជាដៃគូមានកិច្ចសហការល្អជាមួយនឹងព្រឹទ្ធសភា ក្នុងការបើកវគ្គបណ្តុះបណ្តាលពាក់ព័ន្ធដល់វិស័យព័ត៌មាន និងប្រាស្រ័យឆ្លើយឆ្លង
- មានការជួយឧបត្ថម្ភពីដៃគូអភិវឌ្ឍ និងសម្ព័ន្ធភាពជាតិឃុំ-សង្កាត់

ក្នុងការបើកវេទិកា តាមភូមិភាគ

- មានដំណើរទស្សនកិច្ចសិក្សា និងចូលរួមប្រជុំអន្តរជាតិ ដើម្បីស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍លើការងារសភា
- អង្គការអន្តរជាតិជាដៃគូនានាដូចជា **NAIDA, ICT, CIM** បានចូលរួមជួយបំពាក់ប្រព័ន្ធ **Internet** និង **Intranet** ដែលអាចជួយសម្រួលដល់ការស្រាវជ្រាវមួយកម្រិតរបស់មន្ត្រី និងសមាជិកព្រឹទ្ធសភា
- **UNDP** បានជួយរៀបចំ **Internet Café** ដែលអាចជួយសម្រួលដល់ការស្រាវជ្រាវមួយកម្រិតរបស់សមាជិកព្រឹទ្ធសភា
- ប្រព័ន្ធឃោសនាជាតិ-អន្តរជាតិ បានចូលរួមផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពព្រឹទ្ធសភា
- រដ្ឋាភិបាល សភានៃប្រទេសជាមិត្ត ដៃគូអភិវឌ្ឍស្ថាប័ន បានជួយឧបត្ថម្ភសម្ភារបរិក្ខារដល់ព្រឹទ្ធសភា ដូចជា **Computer, Photocopy, Camera** និងជួយកែលំអប្រព័ន្ធ **Studio** និងជួយដល់ការបណ្តុះបណ្តាលធនធានមនុស្ស ...
- សភាបរទេស សហភាពអន្តរសភា **(IPU)** អង្គការអន្តរសភាអាស៊ាន **(AIPA)** សមាគមសភានៃប្រទេសប្រើភាសាបារាំង **(APF)** និងក្រុមមិត្តភាពសភាអន្តរជាតិផ្សេងទៀត បានផ្តល់ការគាំទ្រ និងមានទំនាក់ទំនងល្អជាមួយនឹងព្រឹទ្ធសភា។

## ៣.៦.២ ការគម្រាមកំហែង

- លទ្ធភាពថវិកាជាតិមានកម្រិត ពុំអាចផ្គត់ផ្គង់បានចំពោះសេចក្តីត្រូវការរបស់ព្រឹទ្ធសភា សម្រាប់ដោះស្រាយមធ្យោបាយធ្វើដំណើរក្នុងការជួបប្រាស្រ័យឆ្លើយឆ្លងជាមួយនឹងម្ចាស់ឆ្នោត និងប្រជាពលរដ្ឋ និងការអភិវឌ្ឍស្ថាប័ន ដូចជាការពង្រីកទីកន្លែងធ្វើការ
- ការបំពាក់មធ្យោបាយ សម្ភារ ការស្រាវជ្រាវប្រមូល និងផ្សព្វ-ផ្សាយព័ត៌មាន...
- ក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន នៅពុំទាន់បើកចំហទូលាយក្នុងការផ្តល់ឯកសារសំខាន់ៗ ដល់គណៈកម្មការជំនាញ និងសមាជិកព្រឹទ្ធសភា
- អង្គការអន្តរជាតិជាដៃគូ ពុំទាន់បានគាំទ្រជាថវិកា ឧបករណ៍ និងសម្ភារ សម្រាប់បង្កើតរោងពុម្ពរបស់ព្រឹទ្ធសភា ដើម្បីរួមចំណែកដល់ការផ្សព្វផ្សាយពីការងាររបស់ព្រឹទ្ធសភា ជូនសាធារណជនជាតិ អន្តរជាតិ និងពង្រីកទំនាក់ទំនងសាធារណៈ
- ការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមការិយាល័យរបស់សមាជិកព្រឹទ្ធសភាពុំអាចអនុវត្តបាន ដោយខ្វះថវិកា និងការគាំទ្រពីដៃគូ
- ប្រជាពលរដ្ឋពុំទាន់ចាប់អារម្មណ៍ពីការងារព្រឹទ្ធសភា
- បណ្តាញឃោសនា និងសារព័ត៌មានពុំទាន់បានយល់ដឹងអំពីកិច្ចការសភា ។

# ៤. ស្ថានភាពអនាគត

## ៤.១ ចក្ខុវិស័យ និងបេសកកម្ម

### ៤.១.១ ចក្ខុវិស័យ

ក្នុងរយៈពេល៥ឆ្នាំខាងមុខ (២០១១-២០១៥) ព្រឹទ្ធសភាមានចក្ខុវិស័យធ្វើឱ្យការប្រាស្រ័យឆ្លើយឆ្លងរវាងតំណាង និងម្ចាស់ឆ្នោត សាធារណជនជាតិ និងអន្តរជាតិឱ្យកាន់តែមានជំនឿជឿជាក់ មានភាពជាតំណាងពេញលេញ បើកចំហ មានតម្លាភាព ចូលជិតបាន ចេះរាយការណ៍ និងប្រកបដោយប្រសិទ្ធភាពស្របតាមគោលការណ៍សភាប្រជាធិបតេយ្យលើពិភពលោក។

### ៤.១.២ បេសកកម្ម

ព្រឹទ្ធសភា ត្រូវខិតខំពង្រឹង ពង្រីកចំណងទាក់ទងជាមួយនឹងបណ្ដាក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ សភាប្រជាធិបតេយ្យក្នុងតំបន់ និងលើពិភពលោក ជាពិសេសម្ចាស់ឆ្នោត សាធារណជន ឱ្យគ្រប់ជ្រុងជ្រោយ និងធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយមានគុណភាព ប្រសិទ្ធភាព និងទាន់ពេលវេលា។

## ៤.២ កត្តាកំណត់ជោគជ័យ និងសក្ដានុពលរបស់ព្រឹទ្ធសភា

### ៤.២.១ កត្តាកំណត់ជោគជ័យ

សម្រាប់រយៈពេល៥ឆ្នាំខាងមុខ កត្តាកំណត់ជោគជ័យក្នុងការផ្ដល់សេវាការប្រាស្រ័យឆ្លើយឆ្លងរបស់ព្រឹទ្ធសភាឱ្យមានគុណភាព និងប្រសិទ្ធភាព ព្រឹទ្ធសភា

និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ត្រូវខិតខំយកចិត្តទុកដាក់ និងធានាថា ៖

- ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសាធារណជនមានជំនឿទុកចិត្តលើសមាជិកព្រឹទ្ធសភាដែលជាតំណាងរបស់ខ្លួន
- វេទិកាសាធារណៈ វេទិកាតុមូល និងសិក្ខាសាលារវាងសមាជិកព្រឹទ្ធសភាជាមួយនឹងក្រុមប្រឹក្សាឃុំ-សង្កាត់ សាធារណជនត្រូវបានរៀបចំជាញឹកញាប់នៅក្នុងស្ថាប័នព្រឹទ្ធសភា និងនៅតាមភូមិភាគទាំង៨ ទូទាំងប្រទេស
- មានការចូលរួមយ៉ាងច្រើនកុះករពីក្រុមប្រឹក្សាឃុំ-សង្កាត់ សាធារណជនទូទៅក្នុងវេទិកាសាធារណៈ ដែលគណៈកម្មការជំនាញ និងសមាជិកព្រឹទ្ធសភាបានរៀបចំ និងសាធារណជនហ៊ានចូលរួមក្នុងការផ្តល់គំនិត និងបង្ហាញកង្វល់ទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់
- ការស្រាវជ្រាវឯកសារ និងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិករបស់គណៈកម្មការ និងសមាជិកព្រឹទ្ធសភា ជាមួយនឹងស្ថាប័ននានាមានគុណភាព ទាន់ហេតុការណ៍ និងកាត់បន្ថយថវិកា និងពេលវេលាមួយកម្រិតធំ
- ក្រុមប្រឹក្សាឃុំ-សង្កាត់ និងសាធារណជនទូទៅយល់ច្បាស់ពីតួនាទី និងភារកិច្ចរបស់សមាជិកព្រឹទ្ធសភា
- សាធារណជនទទួលបានអត្ថបទច្បាប់ បទពិពណ៌នា និងពន្យល់ខ្លីៗ

លើមាត្រាសំខាន់ៗនៃច្បាប់ ទស្សនាវដ្ដី ព្រឹត្តិបត្រព្រឹទ្ធសភា។ល។ ទាន់ពេលវេលា និងចូលចិត្តអាន

- សាធារណជនតាមដានការផ្សព្វផ្សាយព័ត៌មានព្រឹទ្ធសភាតាមកម្មវិធីវិទ្យុ ទូរទស្សន៍ និងគេហទំព័រ
- សមត្ថភាពជំនាញរបស់មន្ត្រីទទួលបន្ទុកខាងសរសេរព័ត៌មាន និងនិពន្ធអត្ថបទទស្សនាវដ្ដី ព្រឹត្តិបត្រមានគុណភាពប្រហាក់ប្រហែលនឹងអាជីពរបស់អ្នកសារព័ត៌មាន
- អ្នកសារព័ត៌មានយល់ច្បាស់អំពីការងារព្រឹទ្ធសភា និងផ្សព្វផ្សាយព័ត៌មានបានត្រឹមត្រូវ
- បង្កើតមជ្ឈមណ្ឌលច្បាប់ បណ្ណាល័យទំនើប មជ្ឈមណ្ឌលព័ត៌មានមានសមត្ថភាពធានានូវលំហូរព័ត៌មានឱ្យបានរហ័ស។

## ៤.២.២ សក្ដានុពល

ព្រឹទ្ធសភា មានថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់លើការងារប្រាស្រ័យឆ្លើយឆ្លង មានសាមគ្គីភាពផ្ទៃក្នុងល្អ និងមានកិច្ចសហការជាមួយនឹងរដ្ឋសភា រាជរដ្ឋាភិបាល សភាបរទេស និងដៃគូអន្តរជាតិបានល្អ។ ទន្ទឹមនឹងនោះដែរ ព្រឹទ្ធសភាកសាងបាននូវផែនការយុទ្ធសាស្ត្រ ៥ឆ្នាំ (២០០៣-២០០៨) និងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០០៨-២០១៨) និងបានកៀរគរជំនួយពីបរទេស ដើម្បីអភិវឌ្ឍស្ថាប័នជាលំដាប់ ។ ដោយឡែកអង្គការជាដៃគូមានកិច្ចសហការ

ល្អជាមួយនឹងព្រឹទ្ធសភា ក្នុងការបើកវគ្គបណ្តុះបណ្តាលពាក់ព័ន្ធដល់វិស័យព័ត៌មាន និងប្រាស្រ័យឆ្លើយឆ្លង ជួយឧបត្ថម្ភក្នុងការបើកវេទិកាតាមភូមិភាគ ដំណើរទស្សនកិច្ចសិក្សា និងចូលរួមប្រជុំអន្តរជាតិ ដើម្បីស្វែងយល់ និងផ្លាស់ប្តូរបទពិសោធន៍លើការងារសភា ព្រមទាំងចូលរួមជួយបំពាក់ប្រព័ន្ធ **Internet** និង **Intranet** ដែលអាចជួយសម្រួលដល់ការស្រាវជ្រាវមួយកម្រិតរបស់មន្ត្រី និងសមាជិកព្រឹទ្ធសភា។ ជាមួយគ្នានេះដែរ រដ្ឋាភិបាលសភានៃប្រទេសជាមិត្តបានជួយឧបត្ថម្ភសម្ភារបរិក្ខារដល់ព្រឹទ្ធសភា ដូចជា **Computer, Photocopy, Camera** និងជួយកែលំអប្រព័ន្ធ **Studio** ដើម្បីអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា ។

### ៤.២.៣ អាទិភាពចម្បង

ព្រឹទ្ធសភា បានកំណត់នូវអាទិភាពជាចម្បងមួយចំនួន ដែលនឹងត្រូវដោះស្រាយ ដើម្បីសម្រេចឱ្យបាននូវបេសកកម្ម និងទទួលការគាំទ្រពីសាធារណជនឱ្យបានកាន់តែល្អប្រសើរនាពេលអនាគត។ អាទិភាពទាំងនោះផ្តោតជាសំខាន់ទៅលើ ÷

- បង្កើនសមត្ថភាពសមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការជំនាញ មន្ត្រីជំនួយការ និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើជំនាញដែលពាក់ព័ន្ធដល់ការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈ ដើម្បីធានាគុណភាពអាចឆ្លើយតបបានតាមតម្រូវការរបស់ព្រឹទ្ធសភា។
- បង្កើនទំនាក់ទំនងរបស់សមាជិកព្រឹទ្ធសភា និងបេសកកម្មជាប្រព័ន្ធនៅមូលដ្ឋាន ដើម្បីជួបប្រាស្រ័យឆ្លើយឆ្លងជាមួយនឹងម្ចាស់ឆ្នោត និងសាធារណជន

នៅតាមភូមិភាគ។

• លើកកម្ពស់ការរៀបចំប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លងរបស់ព្រឹទ្ធសភា និងជំរុញការផ្សព្វផ្សាយព័ត៌មាន អំពីកិច្ចការព្រឹទ្ធសភា ដើម្បីធានាបានលំហូរព័ត៌មានជូនស្ថាប័ន ជូនម្ចាស់ឆ្នោត និងសាធារណជន។

• បង្កើនទំនាក់ទំនងជាមួយនឹងម្ចាស់ឆ្នោត រដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នក្រោមជាតិ ប្រព័ន្ធឃោសនា អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិល ឱ្យកាន់តែប្រសើរជាងមុន។

• ជំរុញទំនាក់ទំនងជាមួយនឹងដៃគូអភិវឌ្ឍ សភាបរទេស និងម្ចាស់ជំនួយ ដើម្បីផ្សព្វផ្សាយព័ត៌មានទៅវិញទៅមក និងកៀរគរជំនួយ សម្រួលដល់ការបណ្តុះបណ្តាល ការរៀបចំដំឡើងប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លង និងសម្រាប់ការអភិវឌ្ឍស្ថាប័ន។

អាទិភាពដែលបានជម្រាបជូនខាងលើ ត្រូវបានរៀបចំទៅជាគោលដៅ និងសកម្មភាពមួយចំនួនដូចមានរៀបរាប់ពិស្តារខាងក្រោមនេះ ÷

## ៤.៤ គោលដៅជាយុទ្ធសាស្ត្រ

ព្រឹទ្ធសភាបានរៀបចំគោលដៅជាយុទ្ធសាស្ត្រ០៥ឆ្នាំ (២០១១-២០១៥) ចំនួន០៥ចំណុចសំខាន់ៗ ដើម្បីសម្រេចឱ្យបាននូវបេសកកម្មដែលមានដូចខាងក្រោម ÷

គោលដៅទី ១ : ការអភិវឌ្ឍធនធានមនុស្ស

*បង្កើនសមត្ថភាពសមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការជំនាញ*

*មន្ត្រីជំនួយការ និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើជំនាញដែលពាក់ព័ន្ធដល់ការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈ ដើម្បីធានាគុណភាពអាចឆ្លើយតបបានតាមតម្រូវការរបស់ព្រឹទ្ធសភា ។*

**គោលដៅទី ២ ៖ ពង្រឹង និងពង្រីកតួនាទីភាពជាតំណាង**

*បង្កើនទំនាក់ទំនងរបស់សមាជិកព្រឹទ្ធសភា និងបេសកកម្មជាប្រព័ន្ធនៅមូលដ្ឋាន ដើម្បីជួបប្រាស្រ័យ ឆ្លើយឆ្លងជាមួយនឹងម្ចាស់ឆ្នោត និងសាធារណជននៅតាមភូមិភាគ ។*

**គោលដៅទី ៣ ៖ ការលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មាន**

*លើកកម្ពស់ការរៀបចំប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លងរបស់ព្រឹទ្ធសភា និងជំរុញការផ្សព្វផ្សាយព័ត៌មានអំពីកិច្ចការព្រឹទ្ធសភា ដើម្បីធានាបានលំហូរព័ត៌មានជូនស្ថាប័ន ជូនម្ចាស់ឆ្នោត និងសាធារណជន ។*

**គោលដៅទី ៤ ៖ ទំនាក់ទំនងសាធារណៈ**

*បង្កើនទំនាក់ទំនងជាមួយនឹងម្ចាស់ឆ្នោត រដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នក្រោមជាតិ ប្រព័ន្ធឃោសនា អង្គការក្រៅរដ្ឋាភិបាល និងសង្គមស៊ីវិលឱ្យកាន់តែប្រសើរជាងមុន ។*

**គោលដៅទី ៥ ៖ កិច្ចសហការអន្តរជាតិ**

*ជំរុញទំនាក់ទំនងជាមួយនឹងដៃគូអភិវឌ្ឍ សភាបរទេស និងម្ចាស់ជំនួយដើម្បីផ្សព្វផ្សាយព័ត៌មានទៅវិញទៅមក និងកៀរគរជំនួយ សម្រួលដល់ការ*

*បណ្ដុះបណ្ដាល ការរៀបចំដំឡើងប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លង និងសម្រាប់ការអភិវឌ្ឍស្ថាប័ន ។*

នៅផ្នែកខាងក្រោមនេះ គោលដៅជាយុទ្ធសាស្ត្របានបង្ហាញអំពីសកម្មភាពសំខាន់ៗដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចគោលដៅនីមួយៗដែលបានកំណត់ ។

## ៤.៥ <u>គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ</u>

### គោលដៅទី ១ : ការអភិវឌ្ឍធនធានមនុស្ស

*បង្កើនសមត្ថភាព សមាជិក សមាជិកាព្រឹទ្ធសភា គណៈកម្មការជំនាញ មន្ត្រីជំនួយការ និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើជំនាញដែលពាក់ព័ន្ធដល់ការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈ ដើម្បីធានាគុណភាពអាចឆ្លើយតបបានតាមតម្រូវការរបស់ព្រឹទ្ធសភា ។*

លក្ខណៈពិសេសចាំបាច់នៃផែនការយុទ្ធសាស្ត្រនេះ គឺការពង្រឹងសមត្ថភាពដល់គណៈកម្មការជំនាញសមាជិក សមាជិកាព្រឹទ្ធសភា មន្ត្រីជំនួយការ មន្ត្រីទទួលបន្ទុកសារព័ត៌មាន និងមន្ត្រីរាជការតាមនាយកដ្ឋាននីមួយៗ ដើម្បីសម្រេចបាននូវលទ្ធផលល្អគួរជាទីពេញចិត្តសម្រាប់ស្ថាប័ន។ ជាការចាំបាច់ត្រូវអភិវឌ្ឍសមត្ថភាពលើសេវាស្រាវជ្រាវ និងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិកមានដូចជាប្រព័ន្ធ Network, Internet, Intranet, E-mail សេវាបោះពុម្ព ប្រព័ន្ធថតសំឡេង និងរូបភាព (Studio) ការនិពន្ធអត្ថបទទស្សនាវដ្តី ព្រឹត្តិបត្រ និង

សមត្ថភាពខាងភាសាបរទេស មានភាសាបារាំង និងអង់គ្លេស ។ ជាមួយគ្នានេះដែរ ក៏ត្រូវបណ្តុះបណ្តាលឱ្យមន្ត្រីពាក់ព័ន្ធនេះថែទាំជួសជុលឧបករណ៍ និងគ្រឿងបរិក្ខារសម្រាប់ដំណើរការ ជាពិសេសទៀតត្រូវបណ្តុះបណ្តាលអ្នកសារព័ត៌មានជាតិឱ្យយល់ដឹងកាន់តែច្បាស់អំពីព្រឹទ្ធសភា ។

### ✪ សកម្មភាពសំខាន់ៗ

♦ អភិវឌ្ឍសមត្ថភាពសមាជិកព្រឹទ្ធសភា និងគណៈកម្មការជំនាញអំពីការប្រាស្រ័យឆ្លើយឆ្លង និងការធ្វើបទសម្ភាសន៍ជាមួយនឹងបណ្តាញសារព័ត៌មាន

♦ រៀបចំកម្មវិធីបណ្តុះបណ្តាលគណៈកម្មការជំនាញ សមាជិកព្រឹទ្ធសភា មន្ត្រីជំនួយការ មន្ត្រីតាមនាយកដ្ឋាននីមួយៗឱ្យចេះប្រើប្រាស់ ស្រាវជ្រាវ និងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក មានប្រព័ន្ធNetwork, Internet, Intranet, E-mail ។ល។

♦ រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញព័ត៌មាន និងជំនាញប្រាស្រ័យឆ្លើយឆ្លង

♦ បណ្តុះបណ្តាលមន្ត្រីលើជំនាញនិពន្ធ យកព័ត៌មាន និងសរសេរអត្ថបទព័ត៌មាន ថតរូបភាព ទស្សនាវដ្តី ព្រឹត្តិបត្រ ព្រមទាំងអត្ថបទសម្រាប់យកទៅផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ជំនាញបោះពុម្ព រចនាម៉ូដក្នុងកុំព្យូទ័រ ជំនាញប្រាស្រ័យឆ្លើយឆ្លង ផ្តល់បទសម្ភាសន៍ ដើម្បីអាចមានសមត្ថភាពធ្វើជាអ្នកនាំពាក្យរបស់ស្ថាប័ន

♦ រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកបច្ចេកទេសខាងបោះពុម្ព ស្ទូឌីយ៉ូវិទ្យុ ស្ទូឌីយ៉ូទូរទស្សន៍ក្នុងស្ថាប័ន

♦ បណ្តុះបណ្តាលមន្ត្រីលើជំនាញប្រព័ន្ធថតសំឡេង និងរូបភាព (Studio)

♦ បណ្តុះបណ្តាលមន្ត្រីលើជំនាញថែទាំជួសជុលឧបករណ៍ សម្ភារ និងបរិក្ខារអេឡិចត្រូនិក ដែលបម្រើការប្រាស្រ័យឆ្លើយឆ្លងសាធារណៈ

♦ បណ្តុះបណ្តាលភាសាអង់គ្លេស និងបារាំង ដល់សមាជិកព្រឹទ្ធសភា មន្ត្រីជំនួយការ ដើម្បីមានសមត្ថភាពបកប្រែ ស្រាវជ្រាវព័ត៌មាន និងឯកសារ

♦ បណ្តុះបណ្តាលអ្នកសារព័ត៌មានជាតិ ដើម្បីឱ្យបានយល់ដឹងកាន់តែច្បាស់ពីកិច្ចការព្រឹទ្ធសភា (វប្បធម៌សភា)

♦បណ្តុះបណ្តាលគ្រូបង្គោលអំពីកិច្ចការព្រឹទ្ធសភា ដើម្បីយកទៅផ្សព្វផ្សាយ និងអប់រំសិស្ស និស្សិតនៅតាមគ្រឹះស្ថានសិក្សា និងឧទ្ទេសនាមជូនសាធារណជន ម្ចាស់ឆ្នោត សិក្ខាសាលាទូទាំងភូមិភាគ ។

## គោលដៅទី២ ៖ ពង្រឹង និងពង្រីកតួនាទីភាពជាតំណាង

*បង្កើនទំនាក់ទំនងរបស់សមាជិកព្រឹទ្ធសភា និងបេសកកម្មជាប្រព័ន្ធនៅមូលដ្ឋាន ដើម្បីជួបប្រាស្រ័យឆ្លើយឆ្លងជាមួយនឹងម្ចាស់ឆ្នោត និងសាធារណជននៅតាមភូមិភាគ ។*

សមាជិកព្រឹទ្ធសភា មិនត្រឹមតែជាតំណាងរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់តែប៉ុណ្ណោះទេ ក៏ប៉ុន្តែជាតំណាងរបស់ប្រជាជាតិខ្មែរទាំងមូល ។ ដើម្បីឱ្យតួនាទី

ជាតំណាងអាចបំពេញប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានជំនឿទុកចិត្តពីម្ចាស់ឆ្នោត និងសាធារណជនព្រឹទ្ធសភាត្រូវខិតខំបង្កើនទំនាក់ទំនង និងបេសកកម្មជាប្រព័ន្ធទៅមូលដ្ឋាន អនុវត្តឱ្យកាន់តែប្រសើរឡើងនូវតួនាទីជាតំណាង ដោយត្រូវមានបណ្ដាញត្រឹមត្រូវសម្រាប់បញ្ជូនព័ត៌មានថ្មីៗ ពីមូលដ្ឋានទៅកាន់សមាជិកព្រឹទ្ធសភា និងពីសមាជិកព្រឹទ្ធសភាទៅកាន់មូលដ្ឋាន ព្រមទាំងយកចិត្តទុកដាក់ដោះស្រាយនូវទុក្ខកង្វល់នានារបស់ម្ចាស់ឆ្នោត សាធារណជន រួមទាំងពាក្យបណ្ដឹងផ្សេងៗទៀត។ ទន្ទឹមនេះ ក៏ត្រូវឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ ដោយមានការចូលរួមពីប្រជាពលរដ្ឋម្ចាស់ឆ្នោត អង្គការក្រៅរដ្ឋាភិបាលនានា ដើម្បីចូលរួមផ្ដល់យោបល់ និងបញ្ចេញគំនិតនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់។ ដោយឡែកសមាជិក សមាជិកាព្រឹទ្ធសភា ដែលជាតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ នៅតាមភូមិភាគត្រូវផ្សារភ្ជាប់ជិតស្និទ្ធជាមួយមូលដ្ឋាន តាមរយៈការប្រាស្រ័យឆ្លើយឆ្លងយ៉ាងសកម្មចុះដល់មូលដ្ឋាន និងការរៀបចំវេទិកាផ្សេងៗ ដោយមានកម្មវិធីទៀងទាត់។

## ✪ សកម្មភាពសំខាន់ៗ

✡ ជំរុញសកម្មភាពចុះតាមមណ្ឌលរបស់សមាជិកព្រឹទ្ធសភា ដើម្បីស្ដាប់បានសំណូមពរ ទុក្ខកង្វល់ និងបណ្ដឹងសារទុក្ខរបស់ម្ចាស់ឆ្នោត និងសាធារណជនដោយយកចិត្តទុកដាក់ចូលរួមដោះស្រាយឱ្យបានសមស្រប ដើម្បីបង្កើនជំនឿទុកចិត្តរបស់ម្ចាស់ឆ្នោតលើតំណាងរបស់ខ្លួន

✡ ជំរុញលើកទឹកចិត្តដល់ម្ចាស់ឆ្នោត សាធារណជន សិស្ស និងនិស្សិត ដើម្បីមានឱកាសបានស្គាល់ស្ថាប័នព្រឹទ្ធសភា និងអ្នកតំណាងរបស់ខ្លួនច្បាស់លាស់តាមរយៈទស្សនកិច្ចសិក្សាស្រាវជ្រាវនៅក្នុងបណ្ណាល័យ និងចូលរួមក្នុងកិច្ចពិភាក្សានានារបស់ព្រឹទ្ធសភា ដោយមានការរៀបចំផ្ទាល់របស់ព្រឹទ្ធសភាសហការជាមួយនឹងដៃគូអន្តរជាតិ

✡ បង្កើតឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ រវាងព្រឹទ្ធសភា និងម្ចាស់ឆ្នោត សាធារណជនទូទៅ អំពីការរៀបចំធ្វើច្បាប់ (សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់) ដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមផ្តល់គំនិត និងបង្ហាញលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ

✡ ពង្រឹងសកម្មភាពក្នុងការណែនាំ អនុវត្តកម្មវិធីចុះតាមគ្រឹះស្ថានសិក្សានានា ដើម្បីផ្សព្វផ្សាយ និងអប់រំសិស្ស និស្សិតឱ្យយល់ដឹងអំពីតួនាទីរបស់ព្រឹទ្ធសភា ស្របតាមមុខងារសភាប្រជាធិបតេយ្យ ។

## គោលដៅទី៣ ៖ ការលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មាន

*លើកកម្ពស់ការរៀបចំប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លងរបស់ព្រឹទ្ធសភា និងជំរុញការផ្សព្វផ្សាយព័ត៌មានសំខាន់ៗ អំពីកិច្ចការទាំងឡាយរបស់ព្រឹទ្ធសភា ដើម្បីធានាបានលំហូរព័ត៌មានជូនស្ថាប័នជូនម្ចាស់ឆ្នោត និងសាធារណជន ។*

ការរៀបចំកសាង និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវបានចាត់ទុកថាជាមធ្យោបាយដ៏សំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពការងារ

ប្រាស្រ័យឆ្លើយឆ្លងរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ។ ដើម្បីឱ្យសម្រេចនៅគោលបំណងនេះ ព្រឹទ្ធសភាត្រូវខិតខំរៀបចំដំឡើងប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លង ដែលអាចធ្វើឱ្យមានការផ្លាស់ប្តូរព័ត៌មានបានទាន់ពេលវេលាក្នុងកម្រិតផ្ទៃក្នុងស្ថាប័នជាមួយនឹងរដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ និងសាធារណជន។ ជាមួយនេះដែររៀបចំបង្កើនគុណភាពក្នុងការបោះពុម្ពរបាយការណ៍នានា អត្ថបទច្បាប់ ទស្សនាវដ្តី ព្រឹត្តិបត្រ ប័ណ្ណផ្សព្វផ្សាយ សៀវភៅស្តើង (Brochure) ប័ណ្ណព័ត៌មាន (Leaflet) ។ល ។ សម្រាប់ផ្សព្វផ្សាយជូនសាធារណជនឱ្យបានច្រើន ។ លើកកម្ពស់គុណភាពតាមរយៈការផ្សព្វផ្សាយតាមទស្សនាវដ្តី ព្រឹត្តិបត្រ ប័ណ្ណផ្សព្វផ្សាយសៀវភៅស្តើង (Brochure) ប័ណ្ណព័ត៌មាន (Leaflet) តាមវិទ្យុ ទូរទស្សន៍ ជូនដល់សាធារណជន និងរៀបចំឡើងវិញ និងធ្វើបច្ចុប្បន្នភាពវ៉ិបសាយ (Website) របស់ព្រឹទ្ធសភាឱ្យមានគុណភាពកាន់តែប្រសើរ ។ ការរៀបចំប្រព័ន្ធបណ្តាញសម្រាប់បញ្ជូនសំណើរបស់សាធារណជនមកកាន់ព្រឹទ្ធសភាត្រូវចាត់ទុកវាជាការងារមានសារៈសំខាន់ ។

### ✪ សកម្មភាពសំខាន់ៗ

✦ រៀបចំបណ្តាញព័ត៌មានវិទ្យា (Network E-mail Internet) និងបណ្តាញទូរគមនាគមន៍ មានទូរស័ព្ទ ទូរសារនៅក្នុងអគារការិយាល័យគណៈកម្មការជំនាញ អគារសមាជិកព្រឹទ្ធសភា និងតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីអាចទំនាក់ទំនងព័ត៌មាននៅក្នុងស្ថាប័នបានឆាប់រហ័ស សម្រាប់

ធ្វើការស្រាវជ្រាវ និងទំនាក់ទំនងជាមួយនឹងរដ្ឋសភា អង្គការនីតិប្រតិបត្តិ និង សាធារណជន ។ល។

✦ រៀបចំបណ្ដាញវីដេអូតភ្ជាប់ពីរដ្ឋសភា (Video Link to the National Assembly) ដើម្បីតាមដាន ពីសកម្មភាពប្រជុំពេញអង្គរបស់រដ្ឋសភា

✦ បង្កើតរោងពុម្ពព្រឹទ្ធសភា ដើម្បីមានប្រសិទ្ធភាពក្នុងដំណើរការបោះពុម្ពរបាយការណ៍នានា អត្ថបទច្បាប់ បទពិពណ៌នា និងពន្យល់ខ្លីៗលើមាត្រាសំខាន់ៗនៃច្បាប់ ទស្សនាវដ្ដី ប័ណ្ណផ្សព្វផ្សាយសៀវភៅស្ដើង (Brochure) ប័ណ្ណព័ត៌មាន (Leaflet) ព្រឹត្តិបត្រព្រឹទ្ធសភា ព្រឹត្តិបត្រគណៈកម្មការជំនាញ ។ល។

✦ លើកកម្ពស់គុណភាពប្រព័ន្ធថតសម្លេង និងរូបភាព (Studio) ឱ្យមានលក្ខណៈទំនើប និងប្រសើរជាងមុន ដើម្បីផលិត និងផ្សព្វផ្សាយព័ត៌មានទាំងឡាយរបស់ព្រឹទ្ធសភាជូនប្រជាពលរដ្ឋ និងប្រព័ន្ធឃោសនា

✦ លើកកម្ពស់ការប្រមូល និងផលិតព័ត៌មានតាមគ្រប់រូបភាព អំពីស្ថាប័នព្រឹទ្ធសភា និងអំពីសកម្ម ភាពសមាជិកព្រឹទ្ធសភា

✦ បង្កើនការចុះមូលដ្ឋាន ដើម្បីរាយការណ៍ អំពីសកម្មភាពការងារព្រឹទ្ធសភា ឱ្យម្ចាស់ឆ្នោត សាធារណជន បានជ្រាប

✦ ជំរុញការផ្សព្វផ្សាយ អំពីការងារព្រឹទ្ធសភា នៅតាមគ្រឹះស្ថានសិក្សានានា តាមរយៈការចុះផ្ទាល់របស់សមាជិកព្រឹទ្ធសភា

✦ បង្កើនការផ្សព្វផ្សាយតាមប្រព័ន្ធ **Electronic** (វិទ្យុ ទូរទស្សន៍ និងសារអេឡិចត្រូនិក) និងតាមឯកសារមានការបោះពុម្ពផ្សាយអំពីសកម្មភាពប្រជុំរបស់

ព្រឹទ្ធសភា ការអនុម័តច្បាប់ សកម្មភាពការងាររបស់ សមាជិក សមាជិកាព្រឹទ្ធ-សភា ដើម្បីឱ្យម្ចាស់ឆ្នោត និងសាធារណជនបានជ្រាប ។

## គោលដៅទី ៤ : ទំនាក់ទំនងសាធារណៈ

*បង្កើនទំនាក់ទំនងជាមួយនឹងម្ចាស់ឆ្នោត រដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នក្រោមជាតិ ប្រព័ន្ធឃោសនា អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល និងម្ចាស់ឆ្នោតឱ្យកាន់តែប្រសើរជាងមុន ។*

ការពង្រីកទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា គឺជាយន្តការចាំបាច់មួយ ដែលព្រឹទ្ធសភាត្រូវខិតខំបំពេញឱ្យបានជោគជ័យ ។ កិច្ចការនេះ ព្រឹទ្ធសភាត្រូវខិតខំបំពេញកិច្ចសហការដ៏ល្អរវាងរដ្ឋសភា ស្ថាប័ន នីតិប្រតិបត្តិ ក្រសួងពាក់ព័ន្ធ មានដូចជាក្រសួងអប់រំ យុវជន និងកីឡា ដើម្បីផ្តល់កិច្ចសហការក្នុងការបង្កើត កម្រងមុខវិជ្ជាអំពីតួនាទីព្រឹទ្ធសភានៅតាមគ្រឹះស្ថានសិក្សា។ ប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ពីស្ថាប័នរាជរដ្ឋាភិបាល និងរដ្ឋសភា ដើម្បីប្រសិទ្ធភាពការងារ ។ ទន្ទឹមនោះ ត្រូវខិតខំកសាងសម្ព័ន្ធភាពជាផ្លូវការ រវាងអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល សម្ព័ន្ធភាពជាតិឃុំ-សង្កាត់ សមាគមក្រុមប្រឹក្សាឃុំ-សង្កាត់ និងបង្កើនទំនាក់ទំនងរបស់សមាជិកព្រឹទ្ធសភា ជាមួយនឹងប្រជាពលរដ្ឋ និងម្ចាស់ឆ្នោតនៅតាមភូមិភាគ ។ ដោយឡែក ការបង្កើនកិច្ចសហការជាមួយនឹងប្រព័ន្ធឃោសនាជាគោលដៅមួយដ៏សំខាន់របស់ព្រឹទ្ធសភា ។

ទំនាក់ទំនងរវាងស្ថាប័នពាក់ព័ន្ធខាងលើ ព្រឹទ្ធសភានឹងអាចទទួលបាន

ព័ត៌មានទាន់ពេលវេលា និងច្បាស់លាស់ ដែលអាចអនុវត្តមុខងារជាតំណាង និងមុខងារត្រួតពិនិត្យប្រកបដោយជោគជ័យ ។

### ✪ សកម្មភាពសំខាន់ៗ

◆ បង្កើនទំនាក់ទំនងជាមួយនឹងរដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ដើម្បីស្វែងយល់ការងារសភា និងកិច្ចការរបស់រដ្ឋាភិបាល និងផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញមក

◆ សហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា រៀបចំ និងបង្កើតកម្រងមុខវិជ្ជា អំពីតួនាទីព្រឹទ្ធសភា នៅតាមគ្រឹះស្ថានសិក្សា ចាប់ពីកម្រិតមធ្យមសិក្សាឡើងទៅ

◆ កសាងសម្ព័ន្ធភាពជាផ្លូវការរវាងអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល សម្ព័ន្ធភាពជាតិឃុំ-សង្កាត់ សមាគមក្រុមប្រឹក្សាឃុំ-សង្កាត់ តាមរាជធានីខេត្តនានាជាមួយនឹងព្រឹទ្ធសភា

◆ បង្កើនកិច្ចសហការជាមួយនឹងប្រព័ន្ធឃោសនា ដើម្បីជួយផ្សព្វផ្សាយអំពីការងារព្រឹទ្ធសភា ប្រកបដោយវិជ្ជាជីវៈ

◆ រៀបចំយន្តការទំនាក់ទំនងព័ត៌មានទៅវិញទៅមករវាងព្រឹទ្ធសភាជាមួយនឹងម្ចាស់ឆ្នោតនៅតាមភូមិភាគ ។

## គោលដៅទី ៥ : កិច្ចសហការអន្តរជាតិ

*បង្កើនទំនាក់ទំនងជាមួយនឹងដៃគូអភិវឌ្ឍ សភាបរទេស និងម្ចាស់ជំនួយ*

*ដើម្បីផ្សព្វផ្សាយព័ត៌មានទៅវិញទៅមក និងកៀរគរជំនួយឧបត្ថម្ភដល់ការបណ្តុះបណ្តាល និងការរៀបចំដំឡើងប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លងក្នុងស្ថាប័ន។*

ចំណុចសំខាន់នៃគោលដៅនេះ គឺធ្វើយ៉ាងណាឱ្យសភា រដ្ឋាភិបាលបរទេស អង្គការអន្តរសភា និងម្ចាស់ជំនួយស្គាល់ពីកិត្យានុភាពនៃស្ថាប័នព្រឹទ្ធសភា នៅលើឆាកអន្តរជាតិ ទទួល និងផ្សព្វផ្សាយព័ត៌មានជូនគ្នាទៅវិញទៅមក ព្រមទាំងការកៀរគរជំនួយពីម្ចាស់ជំនួយ ពីដៃគូអភិវឌ្ឍ សភាបរទេស ដើម្បីដំឡើងប្រព័ន្ធប្រើប្រាស់ ចំណាយទៅលើការបណ្តុះបណ្តាល អភិវឌ្ឍសមត្ថភាពដល់មន្ត្រីបុគ្គលិកលើជំនាញបច្ចេកវិទ្យាព័ត៌មាន និងជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធ និងបណ្តុះបណ្តាលបុគ្គលិកឱ្យចេះថែទាំ ជួសជុលឧបករណ៍ និងបរិក្ខារអេឡិចត្រូនិកផងដែរ។ម្យ៉ាងទៀត ហិរញ្ញប្បទានចំណាយដល់ការទិញម៉ោងផ្សព្វផ្សាយព័ត៌មាន តាមវិទ្យុ និងទូរទស្សន៍ក៏ជាកត្តាចាំបាច់ដែរ។

### ✪ សកម្មភាពសំខាន់ៗ

❖ បង្កើនកិច្ចសហការជាមួយនឹងស្ថាប័ន សភាបរទេស ដើម្បីជួយគាំទ្រ និងផ្លាស់ប្តូរបទពិសោធន៍ ការផ្សព្វផ្សាយព័ត៌មានរវាងស្ថាប័នសភាបរទេសជាមួយនឹងព្រឹទ្ធសភាកម្ពុជា

❖ ធ្វើឱ្យប្រសើរឡើងទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលនៃប្រទេសជាមិត្តដើម្បីជួយគាំទ្រ និងផ្លាស់ប្តូរការផ្សព្វផ្សាយព័ត៌មានទៅវិញទៅមក រវាងរដ្ឋាភិបាលបរទេស និងស្ថាប័នព្រឹទ្ធសភា

❖ លើកកម្ពស់ទំនាក់ទំនងជាមួយនឹងអង្គការអន្តរសភា អង្គការអន្តរជាតិ

ដៃគូអភិវឌ្ឍ ដើម្បីជួយគាំទ្រ និងផ្លាស់ប្តូរកិច្ចសហការ និងព័ត៌មាន រវាងព្រឹទ្ធសភា អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ

❖ បង្កើនសហប្រតិបត្តិការជាមួយនឹងសភា និងរដ្ឋាភិបាលបរទេសជាមិត្ត អង្គការអន្តរសភា អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍអន្តរជាតិ ជួយឧបត្ថម្ភគាំទ្រលើផ្នែកបច្ចេកទេស សម្ភារ និងបរិក្ខារ ដើម្បីលើកកម្ពស់ការប្រាស្រ័យឆ្លើយឆ្លងរបស់ស្ថាប័នព្រឹទ្ធសភា ។

## ៥. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រ ស្តីពីការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា រយៈពេល៥ឆ្នាំ (២០១១-២០១៥) បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីគោលដៅ និងគោលបំណងរួមរបស់ព្រឹទ្ធសភា ទាំងមូល ដែលជាមូលដ្ឋានសម្រាប់ជួយបំពេញការងារឱ្យបានសមស្របនៅពេលខាងមុខ និងបានឆ្លើយតបទៅនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពព្រឹទ្ធសភាកម្ពុជា (២០០៨-២០១៨) ។

ដើម្បីធានាឱ្យផែនការយុទ្ធសាស្ត្រនេះទទួលបានជោគជ័យ ព្រឹទ្ធសភាត្រូវខិតខំដោះស្រាយបញ្ហាលំបាកៗមួយចំនួន ដែលជាឧបសគ្គទាក់ទងទៅនឹងការកសាងធនធានមនុស្ស អភិវឌ្ឍន៍សមត្ថភាពដល់សមាជិក សមាជិកាព្រឹទ្ធសភា មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីធានាថាសមាជិកព្រឹទ្ធសភាមានធនធាន និងឧបករណ៍ មធ្យោបាយគ្រប់គ្រាន់សម្រាប់បំពេញការងារឱ្យមានប្រសិទ្ធភាព ។ ទន្ទឹមនឹងនេះ ព្រឹទ្ធសភាត្រូវពង្រឹងពង្រីកការផ្សព្វផ្សាយ

ព័ត៌មានទាំងក្នុង និងក្រៅស្ថាប័នឱ្យបានទូលំទូលាយថែមទៀត ។

យើងចាត់ទុកថា ធនធានមនុស្សពុំទាន់មានសមត្ថភាពខ្ពស់ ការខ្វះខាតឧបករណ៍ សម្ភារមិនគ្រប់គ្រាន់ក្នុងការបំពេញការងារ និងខ្វះឆន្ទៈ អាចមានផលប៉ះពាល់ ដែលចាំបាច់ត្រូវខិតខំជម្នះឱ្យបាននូវរាល់បញ្ហាទាំងនេះ ។

នៅក្នុងផែនការយុទ្ធសាស្ត្រនេះ ព្រឹទ្ធសភាបានដាក់ចេញនូវគោលដៅ និងសកម្មភាពសំខាន់ៗមួយចំនួន ដែលឆ្លុះបញ្ចាំងឱ្យឃើញអំពីចក្ខុវិស័យ បេសកកម្មដ៏វែងឆ្ងាយរបស់ព្រឹទ្ធសភា ដើម្បីឈានទៅបង្កើតមជ្ឈមណ្ឌលព័ត៌មានដ៏រឹងមាំ ជាទ្វារក្នុងការពង្រីកទំនាក់ទំនងសាធារណៈរបស់ព្រឹទ្ធសភា ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ ស្របតាមការវិវត្ត និងការរីកចម្រើនរបស់ស្ថាប័នកំពូលរបស់ជាតិ ។

ដើម្បីសម្រេចគោលដៅទាំងនេះ ព្រឹទ្ធសភាត្រូវខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការខ្ពស់ជាមួយនឹងដៃគូក្នុង និងក្រៅប្រទេស ។ ការបំពាក់មធ្យោបាយប្រកបដោយតុល្យភាព ត្រូវដើរទន្ទឹមគ្នានឹងដំណើរការ បណ្តុះបណ្តាលជំនាញតាមជំហាននីមួយៗ ។

# ផែនការយុទ្ធសាស្ត្រប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈ
# របស់ព្រឹទ្ធសភា រយៈពេល៥ឆ្នាំ ២០១១-២០១៥
# តារាងសង្ខេបលំអិតអំពី គោលដៅ សកម្មភាព ពេលវេលា ធនធាន លទ្ធផលរំពឹងទុក
# សន្ទត់ស្ថានភាពអំណោយផល និងហានិភ័យដែលអាចកើតមាន

<table>
<tr><th>គោលដៅ ទី១</th><th>កម្មវិធី</th><th>លទ្ធផលរំពឹងទុក<br>(លទ្ធផលរំពឹងទុកនេះ ជា លទ្ធផលដែលគ្របដណ្តប់លើស កម្មភាពភាគច្រើន)</th><th colspan="5">ពេលវេលា<br>(អនុវត្តគម្រោង)</th><th>ធនធាន<br>(សម្រាប់អនុវត្តគម្រោង)</th><th>សន្ទត់ស្ថានភាព អំណោយផល និង ហានិភ័យដែលអាច កើតមាន</th></tr>
<tr><td rowspan="2"></td><td rowspan="2">ការអភិវឌ្ឍធនធានមនុស្ស<br>បង្កើនសមត្ថភាព សមាជិក សមាជិកា ព្រឹទ្ធសភា គណៈកម្មការជំនាញ មន្ត្រី</td><td rowspan="2">សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា មានសមត្ថភាពគ្រប់</td><td colspan="5">២០១១-២០១៥</td><td rowspan="2">-ព្រឹទ្ធសភា<br>-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា</td><td rowspan="2"><u>ស្ថានភាពអំណោយផល</u><br>-ផែនការយុទ្ធសាស្ត្រនេះមាន ការគាំទ្រស្មារតី សម្ភារពី</td></tr>
<tr><td>២<br>០</td><td>២<br>០</td><td>២<br>០</td><td>២<br>០</td><td>២<br>០</td></tr>
</table>

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ជំនួយការ និងមន្ត្រីអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើជំនាញដែលពាក់ព័ន្ធដល់ការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈ ដើម្បីធានាគុណភាពអាចឆ្លើយតបបានតាមតម្រូវការរបស់ព្រឹទ្ធសភា ។ | គ្រាន់ក្នុងការប្រាស្រ័យឆ្លើយឆ្លង និងទំនាក់ទំនងសាធារណៈ។ | ១១ | ១២ | ១៣ | ១៤ | ១៥ | -ដៃគូជាតិ អន្តរជាតិ | ព្រឹទ្ធសភា និងដៃគូអភិវឌ្ឍ ។<br>**ហានិភ័យដែលអាចកើតមាន**<br>-ផែនការនេះមិនអាចសម្រេចបានដោយកង្វះធនធានមនុស្ស និងធនធានថវិកា។ |
| **សកម្មភាព** | ១.១អភិវឌ្ឍសមត្ថភាពសមាជិកព្រឹទ្ធសភា និងគណៈកម្មការជំនាញ អំពីការប្រាស្រ័យឆ្លើយឆ្លង និងការធ្វើបទសម្ភាសន៍ជាមួយ នឹងបណ្តាញសារព័ត៌មាន។<br>១.២បណ្តុះបណ្តាលគណៈកម្មការជំនាញ សមាជិកព្រឹទ្ធសភា មន្ត្រីជំនួយការ មន្ត្រីតាមនាយកដ្ឋាននីមួយៗឱ្យចេះប្រើប្រាស់ ស្រាវជ្រាវ និងទំនាក់ទំនងតាមប្រព័ន្ធអេឡិចត្រូនិក | | <br>√ | √<br>√ | √<br> | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | មានព្រ័ន្ធ Network, Internet, Intranet, E-mail ។ល។ | | | | | | | | |
| | **១.៣**បណ្តុះបណ្តាលគ្រូបង្គោលលើជំនាញព័ត៌មាន និងជំនាញប្រាស្រ័យឆ្លើយឆ្លង។ | | | | √ | √ | | | |
| | **១.៤**បណ្តុះបណ្តាលមន្ត្រីលើជំនាញនិពន្ធយកព័ត៌មាន និងសរសេរអត្ថបទព័ត៌មានថតរូបភាព ទស្សនាវដ្តី ព្រឹត្តិបត្រ ព្រមទាំងអត្ថបទសម្រាប់យកទៅផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ ជំនាញបោះពុម្ពរចនាម៉ូដក្នុងកុំព្យូទ័រ ជំនាញប្រាស្រ័យឆ្លើយឆ្លង ផ្តល់បទសម្ភាសន៍ ដើម្បីអាចមានសមត្ថភាពធ្វើជាអ្នកនាំពាក្យរបស់ស្ថាប័ន។ | | | √ | √ | | | | |
| | **១.៥**រៀបចំកម្មវិធីបណ្តុះបណ្តាលសម្រាប់អ្នកបច្ចេកទេសខាងបោះពុម្ព | | | √ | √ | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ស្ទូឌីយ៉ូវិទ្យុ ស្ទូឌីយ៉ូទូរទស្សន៍ក្នុងស្ថាប័ន។ | | | | | | | | |
| | **១.៦**បណ្ដុះបណ្ដាលមន្ត្រីលើជំនាញប្រព័ន្ធថតសំឡេង និងរូបភាព (Studio)។ | | √ | √ | | | | | |
| | **១.៧**បណ្ដុះបណ្ដាលមន្ត្រីលើជំនាញថែទាំជួសជុល ឧបករណ៍ សម្ភារ និងបរិក្ខារអេឡិចត្រូនិក ដែលបម្រើការប្រាស្រ័យឆ្លើយឆ្លងសាធារណៈ។ | | | √ | √ | | | | |
| | **១.៨**បណ្ដុះបណ្ដាលភាសាអង់គ្លេស និងបារាំង ដល់សមាជិកព្រឹទ្ធសភា មន្ត្រីជំនួយការ សម្រាប់មានសមត្ថភាពបកប្រែស្រាវជ្រាវព័ត៌មាន និងឯកសារ។ | | √ | √ | √ | | | | |
| | **១.៩**បណ្ដុះបណ្ដាលអ្នកសារព័ត៌មានជាតិ ដើម្បីឱ្យបានយល់ដឹងកាន់តែច្បាស់ពីកិច្ចការព្រឹទ្ធសភា (វប្បធម៌សភា)។ | | | | √ | √ | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ១.១០បណ្តុះបណ្តាលគ្រូបង្គោល អំពីកិច្ចការព្រឹទ្ធសភា ដើម្បីយកទៅផ្សព្វផ្សាយ និងអប់រំសិស្ស និស្សិត នៅតាមគ្រឹះស្ថានសិក្សា និងឧទ្ទេសនាមជូនសាធារណជនម្ចាស់ឆ្នោត សិក្ខាសាលាទូទាំងភូមិភាគ ។ | | | | | √ | √ | | |
| **គោលដៅទី២** | **ពង្រឹង និងពង្រីកតួនាទីភាពជាតំណាង**<br>បង្កើនទំនាក់ទំនងរបស់សមាជិកព្រឹទ្ធសភា និងបេសកកម្មជាប្រព័ន្ធនៅមូលដ្ឋាន ដើម្បីជួបប្រាស្រ័យឆ្លើយឆ្លងជាមួយនឹងម្ចាស់ឆ្នោត និងសាធារណជននៅតាមភូមិភាគ ។ | ម្ចាស់ឆ្នោត សាធារណជន សិស្សនិស្សិត បានស្គាល់ និងមានទំនាក់ទំនងជាមួយនឹងសមាជិកព្រឹទ្ធ-សភា ដើម្បីពិភាក្សា ពិគ្រោះយោបល់លើបញ្ហាផ្សេងៗ ។ | | | | | | -ព្រឹទ្ធសភា<br>-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>-ដៃគូជាតិ អន្តរជាតិ | <u>**ស្ថានភាពអំណោយផល**</u><br>-ផែនការយុទ្ធសាស្ត្រនេះមានការគាំទ្រស្មារតី សម្ភារ អ.ព.ស និងដៃគូអភិវឌ្ឍ ។<br><u>**ហានិភ័យដែលអាចកើតមាន**</u><br>-កង្វះការចូលរួមពីសមាជិក ព.ស<br>-ខ្វះការប្តេជ្ញាចិត្ត ក្នុងការបំពេញការងារ ។<br>-អ្នករាជការមិនទាន់មានជំនាញគ្រប់គ្រាន់ ។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | -ផែនការនេះមិនអាចសម្រេចបានដោយកង្វះថវិកា។ |
| **សកម្មភាព** | **២.១**ជំរុញសកម្មភាពចុះតាមមណ្ឌលរបស់សមាជិកព្រឹទ្ធសភា ដើម្បីក្តាប់បានសំណូមពរទុក្ខកង្វល់ និងបណ្តឹងសារទុក្ខរបស់ម្ចាស់ឆ្នោត និងសាធារណជន ដោយយកចិត្តទុកដាក់ ចូលរួមដោះស្រាយឱ្យបានសមស្រប ដើម្បីបង្កើនជំនឿទុកចិត្តរបស់ម្ចាស់ឆ្នោតលើតំណាងរបស់ខ្លួន ។ | | √ | √ | | | | | |
| | **២.២**ជំរុញលើកទឹកចិត្តដល់ម្ចាស់ឆ្នោតសាធារណជន សិស្ស និងនិស្សិត ដើម្បីមានឱកាសបាន ស្គាល់ស្ថាប័នព្រឹទ្ធសភា និងអ្នកតំណាងរបស់ខ្លួនច្បាស់លាស់ តាមរយៈទស្សនកិច្ចសិក្សា ស្រាវជ្រាវនៅក្នុងបណ្ណាល័យ និងចូលរួមក្នុងកិច្ច | | | √ | √ | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ពិភាក្សានានារបស់ព្រឹទ្ធសភា ដោយមានការរៀបចំផ្ទាល់របស់ព្រឹទ្ធសភា សហការជាមួយនឹងដៃគូអន្តរជាតិ ។ | | | | | | | | |
| | **២.៣**បង្កើតឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ រវាងព្រឹទ្ធសភា និងម្ចាស់ឆ្នោត សាធារណជនទូទៅ អំពីការរៀបចំធ្វើច្បាប់ (សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់) ដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋចូលរួមផ្តល់គំនិត និងបង្ហាញលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ ។ | | | | | √ | √ | | |
| | **២.៤**ពង្រឹងសកម្មភាពក្នុងការណែនាំអនុវត្តកម្មវិធីចុះតាមគ្រឹះស្ថានសិក្សានានា ដើម្បីផ្សព្វផ្សាយ និងអប់រំសិស្សនិស្សិតឱ្យយល់ដឹងអំពីតួនាទីរបស់ព្រឹទ្ធសភាស្របតាមមុខងារសភា | | | | | √ | √ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រជាធិបតេយ្យ ។ | | | | | | | | |
| **គោលដៅទី៣** | **ការលើកកម្ពស់ការផ្សព្វផ្សាយព័ត៌មាន**<br>លើកកម្ពស់ការរៀបចំប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លងរបស់ព្រឹទ្ធសភា និងជំរុញការផ្សព្វផ្សាយព័តិមាន អំពីកិច្ចការព្រឹទ្ធ-សភា ដើម្បីធានាបានលំហូរព័តិមានជូនស្ថាប័ន ជូនម្ចាស់ឆ្នោត និងសាធា-រណជន ។ | ព្រឹទ្ធសភា មានប្រព័ន្ធផ្សព្វផ្សាយព័តិមាន ជាក់លាក់ ដើម្បីបម្រើជូនសមាជិក សមាជិកាព្រឹទ្ធ-សភា ក្នុងការទទួល និងបញ្ជូនព័តិមាន ជូនគ្រប់ស្ថាប័នម្ចាស់ឆ្នោត និងសាធារណជន | | | | | | -ព្រឹទ្ធសភា<br>-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>-ដៃគូជាតិ-អន្តរជាតិ | <u>**ស្ថានភាពអំណោយផល**</u><br>-ផែនការយុទ្ធសាស្ត្រនេះមានការគាំទ្រស្មារតី សម្មារពីព្រឹទ្ធសភា និងដៃគូអភិវឌ្ឍ ។<br><u>**ហានិភ័យដែលអាចកើតមាន**</u><br>-មធ្យោបាយ ធនធាន សម្ភារនៅមានកម្រិត ។<br>-ខ្វះថវិកា និងឆន្ទៈក្នុងការបំពេញ ការងារ ។ |
| **សកម្មភាព** | ៣.១រៀបចំបណ្តាញព័តិមានវិទ្យា (Network E-mail Internet) និងបណ្តាញទូរគមនាគមន៏ មានទូរស័ព្ទ ទូរសារនៅក្នុងអគារការិយាល័យ គណៈ-កម្មការជំនាញ អគារសមាជិកព្រឹទ្ធ-សភា និងតាមអង្គភាពចំណុះអគ្គ | | | | | √ | √ | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | លេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីអាចទំនាក់ទំនងព័តិមាននៅក្នុងស្ថាប័នបានឆាប់រហ័ស សម្រាប់ធ្វើការស្រាវ-ជ្រាវ និងទំនាក់ទំនងជាមួយនឹងរដ្ឋសភា អង្គការនីតិប្បញ្ញត្តិ និងសាធារណជន ។ល ។<br>**៣.២**រៀបចំបណ្តាញវីដេអូតភ្ជាប់ពីរដ្ឋសភា (Video Link to the National Assembly) ដើម្បីតាមដានពីសកម្មភាពប្រជុំពេញអង្គរបស់រដ្ឋសភា ។<br>**៣.៣**បង្កើតរោងពុម្ពព្រឹទ្ធសភា ដើម្បីមានប្រសិទ្ធភាព ក្នុងដំណើរការបោះពុម្ពរបាយការណ៍នានា អត្ថបទច្បាប់ បទពិពណ៌នា និងពន្យល់ខ្លីៗលើមាត្រាសំខាន់ៗនៃច្បាប់ ទស្សនាវដ្តី ព្រឹត្តិបត្រព្រឹទ្ធសភា ព្រឹត្តិបត្រគណៈ- | | | | | √<br>√ | √<br>√ | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | កម្មការជំនាញ ។ល ។ | | | | | | | | |
| | **៣.៤**លើកកម្ពស់គុណភាពប្រព័ន្ធថតសំឡេង និងរូបភាព (Studio) ឱ្យមានលក្ខណៈទំនើប និងប្រសើរជាងមុន ដើម្បីផលិត និងផ្សព្វផ្សាយព័ត៌មានទាំងឡាយរបស់ព្រឹទ្ធសភា ជូនប្រជាពលរដ្ឋ និងប្រព័ន្ធឃោសនា ។ | | | √ | √ | | | | |
| | **៣.៥**លើកកម្ពស់ការប្រមូល និងផលិតព័ត៌មានតាមគ្រប់រូបភាព អំពីស្ថាប័នព្រឹទ្ធសភា និងអំពីសកម្មភាពសមាជិកព្រឹទ្ធសភា ។ | | √ | √ | | | | | |
| | **៣.៦**បង្កើនការចុះមូលដ្ឋាន ដើម្បីរាយការណ៍អំពីសកម្មភាពការងារព្រឹទ្ធសភា ឱ្យម្ចាស់ឆ្នោត សាធារណជនបានជ្រាប ។ | | √ | √ | | | | | |
| | **៣.៧**ជំរុញការផ្សព្វផ្សាយអំពីការងារព្រឹទ្ធសភា | | | | √ | √ | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | នៅតាមគ្រឹះស្ថានសិក្សានានា តាមរយៈការចុះផ្ទាល់របស់សមាជិកព្រឹទ្ធសភា ។ **៣.៨**បង្កើនការផ្សព្វផ្សាយតាមប្រព័ន្ធ Electronic (វិទ្យុ ទូរទស្សន៍ និងសារអេឡិចត្រូនិក) និងតាមឯកសារមានការបោះពុម្ពផ្សាយអំពីសកម្មភាពប្រជុំរបស់ព្រឹទ្ធសភា ការអនុម័តច្បាប់ សកម្មភាពការងាររបស់សមាជិក សមាជិកាព្រឹទ្ធ-សភា ដើម្បីឱ្យម្ចាស់ឆ្នោត និងសាធារណជនបានជ្រាប ។ | | | | | √ | √ | | |
| **គោលដៅទី៤** | **ទំនាក់ទំនងសាធារណៈ** បង្កើនទំនាក់ទំនងជាមួយនឹងម្ចាស់ឆ្នោត រដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ស្ថាប័នថ្នាក់ក្រោមជាតិ ប្រព័ន្ធឃោសនា អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល | ទទួលបានកិច្ចសហប្រតិបត្តិការល្អជាមួយនឹងក្រសួង ស្ថាប័ននានា ជាពិសេសអ្នកសារព័ត៌មានជាតិ អន្តរជាតិ ដើម្បីឱ្យពួកគេសហការ ក្នុងការ | | | | | | -ព្រឹទ្ធសភា<br>-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>-ដៃគូជាតិ-អន្តរជាតិ | <u>**ស្ថានភាពអំណោយផល**</u><br>-ផែនការយុទ្ធសាស្ត្រនេះមានការគាំទ្រស្មារតី សម្ភារពីព្រឹទ្ធសភា និងដៃគូអភិវឌ្ឍ ។<br><u>**ហានិភ័យដែលអាចកើតមាន**</u> |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | និងម្ចាស់ឆ្នោតឱ្យកាន់តែប្រសើរជាងមុន។ | ផ្សព្វផ្សាយព័ត៌មានរបស់ព្រឹទ្ធ-សភា។ | | | | | | | -សមត្ថភាពជំនាញនៅពុំទាន់គ្រប់គ្រាន់។<br>-ខ្វះថវិកា និងឆន្ទៈក្នុងការបំពេញការងារ។ |
| **សកម្មភាព** | **៤.១**បង្កើនទំនាក់ទំនងជាមួយនឹងរដ្ឋសភា ស្ថាប័ននីតិប្រតិបត្តិ ដើម្បីស្វែងយល់ការងារសភា និងកិច្ចការរបស់រដ្ឋាភិបាល និងផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញមក។ | | √ | √ | | | | | |
| | **៤.២**សហការជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា រៀបចំ និងបង្កើតកម្រងមុខវិជ្ជា អំពីតួនាទីព្រឹទ្ធសភានៅតាមគ្រឹះស្ថានសិក្សាចាប់ពីកម្រិតមធ្យមសិក្សាឡើងទៅ។ | | | | √ | √ | √ | | |
| | **៤.៣**កសាងសម្ព័ន្ធភាពជាផ្លូវការវាងអង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល | | √ | √ | √ | | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សម្ព័ន្ធភាពជាតិឃុំ-សង្កាត់ សមាគមក្រុមប្រឹក្សាឃុំ-សង្កាត់ តាមរាជធានីខេត្តនានា ជាមួយនឹងព្រឹទ្ធសភា។<br>**៤.៤**បង្កើនកិច្ចសហការជាមួយនឹងប្រព័ន្ធឃោសនា ដើម្បីជួយផ្សព្វផ្សាយអំពីការងារព្រឹទ្ធសភាប្រកបដោយវិជ្ជាជីវៈ។<br>**៤.៥**រៀបចំយន្តការទំនាក់ទំនងព័ត៌មានទៅវិញ-ទៅមករវាងព្រឹទ្ធសភាជាមួយនឹងម្ចាស់ឆ្នោតនៅតាមភូមិភាគ។ | | | √ | √<br>√ | √ | | | |
| **គោលដៅទី៥** | **កិច្ចសហការអន្តរជាតិ**<br>បង្កើនទំនាក់ទំនងជាមួយនឹងដៃគូអភិវឌ្ឍ សភាបរទេស និងម្ចាស់ជំនួយ ដើម្បីផ្សព្វផ្សាយព័ត៌មានទៅវិញ ទៅមក និងកៀរគរជំនួយឧបត្ថម្ភដល់ការបណ្តុះបណ្តាល និងការរៀបចំដំឡើងប្រព័ន្ធប្រាស្រ័យឆ្លើយឆ្លងក្នុងស្ថាប័ន។ | ទទួលបានកិច្ចសហប្រតិបត្តិការល្អជាមួយនឹងដៃគូអភិវឌ្ឍ សភាបរទេស ម្ចាស់ជំនួយ ដើម្បីទទួល និងផ្សព្វផ្សាយព័ត៌មានទៅវិញ ទៅមក។ | | | | | | -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា<br>-ដៃគូជាតិ-អន្តរជាតិ | **<u>ស្ថានភាពអំណោយផល</u>**<br>-ផែនការយុទ្ធសាស្ត្រនេះមានការគាំទ្រស្មារតី សម្ភារពីព្រឹទ្ធសភា និងដៃគូអភិវឌ្ឍ។<br>**<u>ហានិភ័យដែលអាចកើតមាន</u>**<br>-សមត្ថភាពជំនាញនៅពុំទាន់គ្រប់គ្រាន់។ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | -ខ្វះថវិកា និងឆន្ទៈក្នុងការបំពេញការងារ ។ |
| **សកម្មភាព** | **៥.១**បង្កើនកិច្ចសហការជាមួយនឹងស្ថាប័ន សភាបរទេស ដើម្បីជួយគាំទ្រ និងផ្លាស់ប្តូរបទពិសោធន៍ ការផ្សព្វផ្សាយព័ត៌មានរវាងស្ថាប័នសភាបរទេសជាមួយនឹងព្រឹទ្ធសភាកម្ពុជា ។ | | √ | √ | | | | | |
| | **៥.២**ធ្វើឱ្យប្រសើរឡើងទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលនៃប្រទេសជាមិត្ត ដើម្បីជួយគាំទ្រ និងផ្លាស់ប្តូរការផ្សព្វ-ផ្សាយព័ត៌មានទៅវិញទៅមករវាងរដ្ឋាភិបាលបរទេស និងស្ថាប័នព្រឹទ្ធ-សភា ។ | | | √ | √ | | | | |
| | **៥.៣**លើកកម្ពស់ទំនាក់ទំនងជាមួយនឹងអង្គការអន្តរសភា អង្គការអន្តរជាតិដៃគូអភិវឌ្ឍ ដើម្បីជួយគាំទ្រ និងផ្លាស់ | | | | √ | √ | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | ប្តូរកិច្ចសហការ និងព័ត៌មាន រវាងព្រឹទ្ធសភា អង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍ<br>**៥.៤**បង្កើនសហប្រតិបត្តិការជាមួយនឹងសភា និងរដ្ឋាភិបាលបរទេសជាមិត្ត អង្គការអន្តរសភា អង្គការសហប្រជាជាតិ និងដៃគូអភិវឌ្ឍអន្តរជាតិ ជួយឧបត្ថម្ភគាំទ្រ លើផ្នែកបច្ចេកទេស សម្ភារ និងបរិក្ខារ ដើម្បីលើកកម្ពស់ការប្រាស្រ័យឆ្លើយឆ្លងរបស់ស្ថាប័នព្រឹទ្ធសភា។ | | | | | √ | √ | | |